ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបរធនបាលកិច្ច**

លេខ: ០០៣/២២ ន.ប.ធ./ស.ជ.ណ.

# សេចក្តីជូនដំណឹង
## ស្តីពី
## ការទទួលចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច លើកទី១

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិសម្រាប់ក្រុមហ៊ុនបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនបរធនបាល ក្រុមហ៊ុនផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសាធារណៈជនទាំងអស់មេត្តាជ្រាបថា÷ **ន.ប.ធ.** នឹងចាប់ផ្តើមទទួលពាក្យចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ លើកទី១ ចាប់ពីថ្ងៃចេញលិខិតជូនដំណឹងនេះតទៅ។ អាស្រ័យហេតុនេះ បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិទាំងអស់ សូមអញ្ជើញមកចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលនេះ នៅនិយ័តករបរធនបាលកិច្ច ដែលមានទីតាំងនៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាន់ទី៨ អាសយដ្ឋានផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ ០៧៧ ២៧៨ ០១៩/ ០១១ ៧៦ ៦៦ ២៦ ឬអ៊ីមែល÷ info@trustregulator.gov.kh។

**បញ្ជាក់÷** ចំពោះវគ្គបណ្តុះបណ្តាល និងការប្រឡងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិនេះ ត្រូវបង់ថ្លៃចូលរួមចំនួន ៨០០,០០០៛(ប្រាំបីរយពាន់រៀល) ក្នុងមួយនាក់ ប៉ុន្តែសម្រាប់ដំណាក់កាលដំបូង **ន.ប.ធ.** កំណត់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលនេះត្រឹមចំនួន ៤០០,០០០៛ (បួនរយពាន់រៀល) ក្នុងមួយនាក់ ជាបណ្តោះអាសន្នរហូតដល់មានការជូនដំណឹងសារជាថ្មី។ ចំពោះពាក្យស្នើសុំ សូមទាញយកតាមរយៈតំណរនេះ https://qrs.ly/h3duc61 ឬតាមរយៈ QR Code ខាងក្រោម។

**សម្គាល់÷** ចំពោះកាលបរិច្ឆេទក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់ទទួលស្គាល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ **ន.ប.ធ.** នឹងជម្រាបជូននៅពេលក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន និងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

ថ្ងៃចន្ទ ១៤ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២២

**និយ័តករបរធនបាលកិច្ច**

សូមទាញយកពាក្យស្នើសុំនៅទីនេះ!